ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់សាកលវិទ្យាល័យអាយស៊ីអេស

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោកស្រី ឃួន សុដារី ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៤
- បានឃើញយោបល់ របស់ក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

មាត្រា ១.: ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **សាកលវិទ្យាល័យអាយស៊ីអេស** “ **ICS University** ” ហៅកាត់ជាភាសាខ្មែរ “ស.អ.ស.អ.” និង ហៅកាត់ជាភាសាអង់គ្លេស

" I.C.S.U." ។ សាកលវិទ្យាល័យនេះ មានទីតាំងគោលស្ថិតនៅ អាគារលេខ ១៨ ផ្លូវលេខ ២១៤ សង្កាត់បឹងរាំង ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យអាយស៊ីអេស ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣ :** សាកលវិទ្យាល័យអាយស៊ីអេស ធ្វើការបណ្តុះបណ្តាល :

- ជំនាញបច្ចេកទេសរយៈពេលខ្លី ។
- ថ្នាក់ បរិញ្ញាប័ត្ររង សិក្សារយៈពេល ២ ឆ្នាំ ជាមធ្យម ។
- ថ្នាក់ បរិញ្ញាប័ត្រ សិក្សារយៈពេល ៤ ឆ្នាំ ជាមធ្យម ។
- ថ្នាក់ ម៉ាស្ទ័រ សិក្សារយៈពេល ២ ឆ្នាំ ជាមធ្យម ។
- ថ្នាក់ បណ្ឌិត សិក្សាស្រាវជ្រាវ រយៈពេលយ៉ាងតិច ៣ ឆ្នាំ ។

សាកលវិទ្យាល័យអាយស៊ីអេស ត្រូវរៀបចំកម្មវិធីសិក្សាលំអិត ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤ :** សាកលវិទ្យាល័យអាយស៊ីអេស មានមហាវិទ្យាល័យចំនួន ០៦ និង វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសមួយ :

- មហាវិទ្យាល័យ មនុស្សសាស្ត្រ និង ភាសាបរទេស
- មហាវិទ្យាល័យ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា
- មហាវិទ្យាល័យសង្គមសាស្ត្រ និង នីតិសាស្ត្រ
- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជសាស្ត្រ
- មហាវិទ្យាល័យអប់រំ និង ទេសចរណ៍
- មហាវិទ្យាល័យកសិកម្ម
- វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស ។

ទៅអនាគត សាកលវិទ្យាល័យនេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ឬ ប្រភេទបណ្តុះ-បណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥ :** សាកលវិទ្យាល័យអាយស៊ីអេស មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសំរេចលើគោល-នយោបាយ ផែនការអភិវឌ្ឍ អនុម័តលើកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

**មាត្រា ៦ :** សាកលវិទ្យាល័យអាយស៊ីអេស ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការទទួលសិស្ស-និស្សិត ឱ្យចូលរៀន ។

**មាត្រា ៧ :** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអាយស៊ីអេស មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកមកបំរើការងារ ។

- គ្រប់គ្រងឱ្យបានល្អ នូវការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវ ការប្រលង និងការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្តតាមច្បាប់ និង បទដ្ឋានណែនាំ របស់ក្រសួងអប់រំ យុវជន និងកីឡា និង រាជរដ្ឋាភិបាល ។
- ធានាឱ្យបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ឱ្យបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៨** : និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យអាយស៊ីអេស និង ទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រ តាមកំរិត និងតាមឯកទេសដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យអាយស៊ីអេស ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បានបំពេញ និងអនុវត្តតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួង អប់រំ យុវជន និងកីឡា ។

**មាត្រា ៩** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាកលវិទ្យាល័យអាយស៊ីអេស មានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្តតាមអនុក្រឹត្យនេះ ។

**មាត្រា ១០** : អនុក្រឹត្យនេះ មានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ ០៣ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

"ដើម្បីជ្រាប"

- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ